អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើ ការវាយតម្លៃឡើងវិញអំពី សម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ

នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើការ វាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។ ផ្អែកតាមរបាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានតែងតាំងដោយតុលាការ នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចជាថ្មីដោយតម្កល់នូវសេចក្តីសម្រេចរបស់ខ្លួនពីលើកមុនដែលថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជម្ងឺកាន់តែធ្ងន់ធ្ងរឡើងៗ (ជាប្រភេទជម្ងឺអាលហ្សៃម៉ា Alzheimer ដែលជាជម្ងឺវង្វេងវង្វាន់ និងភ្លេចការចងចាំ) ហើយគាត់នៅតែមិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការបាន។ ក្រុមអ្នកជំនាញបានបញ្ជាក់ថា រហូតមកដល់ពេលនេះ ការព្យាបាលតាមគ្រប់មធ្យោបាយត្រូវបានប្រើប្រាស់អស់លទ្ធភាពហើយ ហើយការចុះខ្សោយនៃដំណើរការខួរក្បាលរបស់ជនជាប់ចោទ នៅតែមិនអាចវិលត្រឡប់មកសភាពធម្មតាវិញបានទេ។ ដោយសារតែមិនអាចប៉ាន់ស្មានបានថា ជនជាប់ចោទរូបនេះ នឹងអាចត្រូវយកមកជំនុំជម្រះបាននៅពេលណានោះ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចតម្កល់ការបំបែកកិច្ចនីតិវិធីនូវបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងសំណុំរឿង ០០២ និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទរូបនេះ ដោយមិនកំណត់រយៈពេល។ ដូចដែល សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីបានទទួលស្គាល់ដែរ នៅក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវមានកាតព្វកិច្ចដោះលែងជនជាប់ចោទរូបនេះចេញពីមន្ទីរឃុំឃាំង។

ដោយសារតែ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានផ្អាក ដោយមិនកំណត់រយៈពេល អង្គជំនុំជម្រះសាលាដំបូងមិនមានមូលដ្ឋានតាមផ្លូវច្បាប់ដើម្បីដាក់លក្ខខណ្ឌដោយបង្ខំលើជនជាប់ចោទរូបនេះបានឡើយ នៅពេលដោះលែង។ ដោយសារតែ សមត្ថភាពខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ លក្ខខណ្ឌដោយបង្ខំ ទោះក្នុងករណីណាក៏ដោយ មានការលំបាកក្នុងការអនុវត្ត។ ស្ថានភាពសុខភាពរបស់ជនជាប់ចោទ បានបង្ហាញ

ថា ជនជាប់ចោទមិនមានសមត្ថភាពក្នុងការចងចាំ ឬ អនុវត្តតាមលក្ខខណ្ឌទាំងនេះបានឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានយល់ស្របជាមួយសហព្រះរាជអាជ្ញាក្នុងការដាក់វិធានការជាក់លាក់មួយចំនួននៅពេលដោះលែង ជនជាប់ចោទ អៀង ធីរិទ្ធ នៅមានលក្ខណៈសមស្រប។ ហេតុដូច្នេះ អង្គជំនុំជម្រះបានរំលឹកដល់ជនជាប់ចោទ អំពីកាតព្វកិច្ចរបស់ខ្លួន ដោយមិនត្រូវជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដូចជា មិនត្រូវទាក់ទងជាមួយ សាក្សី, ជនរងគ្រោះ ឬជនជាប់ចោទដទៃទៀត (លើកលែងតែស្វាមីរបស់គាត់ អៀង សារី)។ អង្គជំនុំជម្រះសាលាដំបូងក៏បានស្នើឲ្យជនជាប់ចោទរូបនេះ មិនត្រូវចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា, ត្រូវជូនដំណឹងដល់ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មុននឹងផ្លាស់ប្តូរអាសយដ្ឋានរស់នៅណាមួយរបស់ខ្លួន និង មិនត្រូវទាក់ទងជាមួយប្រព័ន្ធសារព័ត៌មានពាក់ព័ន្ធនឹងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ដោយសារតែជម្ងឺ អាលហ្សៃម៉ា Alzheimer ជាប្រភេទជម្ងឺដែលមិនអាចព្យាបាលបាននាពេលបច្ចុប្បន្ន ហើយក៏មិនមានមធ្យោបាយណាមួយក្នុងការព្យាបាលជម្ងឺនេះតទៅបាននោះ អង្គជំនុំជម្រះមិនបង្គាប់ឲ្យមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្របន្ថែមទៀតទៅលើជនជាប់ចោទរូបនេះទេ។ ប៉ុន្តែអង្គជំនុំជម្រះ យល់ព្រមធ្វើការពិគ្រោះយោបល់ជារៀងរាល់ឆ្នាំជាមួយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលត្រូវបានតែងតាំងដោយតុលាការដើម្បីបញ្ជាក់អំពីលទ្ធភាពនៃការរកឃើញនូវការព្យាបាលតាមបែបវេជ្ជសាស្ត្រថ្មីៗ ដែលតាម យោបល់របស់អ្នកជំនាញថា អាចនឹងជួយស្តារសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទឲ្យចូលរួមក្នុងការជំនុំជម្រះវិញបាន។ ដោយសារតែលទ្ធភាពនៃការរកឃើញនូវការព្យាបាលជំងឺវង្វេងវង្វាន់ (ជម្ងឺអាលហ្សៃម៉ាAlzheimer) នាពេលបច្ចុប្បន្ននេះ មានលក្ខណៈមិនច្បាស់លាស់ ការណ៍នេះនាំឲ្យមិនមានមូលដ្ឋានក្នុងការបន្តឃុំខ្លួនជនជាប់ចោទរូបនេះបានឡើយ។

អង្គជំនុំជម្រះសូមបញ្ជាក់ផងដែរថា សេចក្តីសម្រេចដែលថា ជនជាប់ចោទមិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនេះ មិនមែនជាការសម្រេចសេចក្តីអំពីអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នោះឡើយ ហើយក៏មិនមានអានុភាពដកការចោទប្រកាន់នានាចេញពីជនជាប់ចោទរូបនេះដែរ។

http://www.eccc.gov.kh/document/court/22533

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោកស្រី យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ៣១៩
ទូរស័ព្ទលើតុផ្ទាល់ៈ +៨៥៥ (0) ២៣ ៨៦១ ៦៣៩
សារអេឡិកត្រូនិកៈ maeday@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃៈ +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh